(ការបកប្រែក្រៅផ្លូវការ)

សេចក្តីថ្លែងការណ៍រួម
នៃព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋបារាំង
ក្នុងឱកាសនៃដំណើរទស្សនកិច្ចផ្លូវរដ្ឋរបស់
ឯកឧត្តម អេម៉ានុយអែល ម៉ាក្រុង ប្រធានាធិបតី នៃសាធារណរដ្ឋបារាំង
នៅព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី ១៥-១៦ ខែវិច្ឆិកា ឆ្នាំ ២០២៦

១. តបតាមការអញ្ជើញរបស់**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា **ឯកឧត្តម អេម៉ានុយអែល ម៉ាក្រុង** ប្រធានាធិបតី នៃសាធារណរដ្ឋបារាំង បានអញ្ជើញមកបំពេញទស្សនកិច្ចផ្លូវរដ្ឋ នៅព្រះរាជាណាចក្រកម្ពុជា ពីថ្ងៃទី១៥ ដល់ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៦ និងបានចូលរួមកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី២០ នៅរាជធានីភ្នំពេញ។ ដំណើរទស្សនកិច្ចនេះ បានឆ្លុះបញ្ចាំងពីទំនាក់ទំនងដ៏ពិសេសរវាងប្រទេសទាំងពីរ ដែលបានទទួលមរតកពីប្រវត្តិសាស្ត្ររួម និងតួនាទីរបស់បារាំងក្នុងការនាំមកនូវសន្តិភាពជូនកម្ពុជា និងការកសាងប្រទេសឡើងវិញ ក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ឆ្នាំ១៩៩១។ រយៈពេល ៣៥ឆ្នាំ ក្រោយការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ និង ៦០ឆ្នាំ បន្ទាប់ពីការថ្លែងសុន្ទរកថារបស់ **ឯកឧត្តមឧត្តមសេនីយ៍ ហ្សាល ដឺហ្គោល** នៅរាជធានីភ្នំពេញ ថ្នាក់ដឹកនាំនៃប្រទេសទាំងពីរ បានអះអាងសាជាថ្មី អំពីគោលបំណងឱ្យប្រទេសកម្ពុជាស្ថិតក្នុងសន្តិភាព ការប្តេជ្ញាចិត្តរួមគ្នាចំពោះគោលការណ៍អធិបតេយ្យ និងការការពារតម្លៃនានា ដែលប្រទេសទាំងពីរប្រកាន់ខ្ជាប់រួមគ្នា ក្នុងក្របខ័ណ្ឌនៃការគោរពសិទ្ធិមនុស្ស និងនីតិរដ្ឋ។

២. ក្នុងឱកាសនេះ **ឯកឧត្តមប្រធានាធិបតី** នៃសាធារណរដ្ឋបារាំង និង**សម្តេចធិបតីនាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា បានប្តេជ្ញាជំរុញទំនាក់ទំនងរវាងប្រទេសបារាំង និងប្រទេសកម្ពុជា ក្នុងភាពជាដៃគូថ្មីមួយកម្រិតទៀត ដែលនឹងផ្តល់ជាក្របខ័ណ្ឌសម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគី សម្រាប់រយៈពេលជាច្រើនទសវត្សរ៍ខាងមុខទៀត។ ភាពជាដៃគូនេះ ឆ្លុះបញ្ចាំងពីឆន្ទៈរួមគ្នា ជំរុញទំនាក់ទំនងបារាំង-កម្ពុជាឱ្យកាន់តែរីកចម្រើនក្នុងវិស័យជាច្រើនដូចជា ការផ្លាស់ប្តូររវាងប្រជាជននិងប្រជាជន ការអភិវឌ្ឍសេដ្ឋកិច្ច សន្តិសុខ ព្រមទាំងបញ្ហាប្រឈមជាសកល ដើម្បីផលប្រយោជន៍រួមរបស់ប្រជាជននៃប្រទេសទាំងពីរ និងធ្វើការរួមគ្នាជាសមូហភាពឆ្ពោះទៅរកសន្តិភាព ក្នុងបរិស្ថានសកលមួយ ដែលកាន់តែមិនប្រាកដប្រជាទៅៗ។

កសាងភាពជាដៃគូនយោបាយដ៏រឹងមាំ

៣. ថ្នាក់ដឹកនាំទាំងពីរ បានរំលឹកឡើងវិញនូវក្របខ័ណ្ឌនយោបាយដ៏រឹងមាំ ដែលជាមូលដ្ឋានគ្រឹះនៃទំនាក់ទំនងទ្វេភាគី។ ជម្រៅប្រវត្តិសាស្ត្រនៃទំនាក់ទំនងនេះ បានជំរុញឱ្យមានភាពស្និទ្ធស្នាលផ្នែកវប្បធម៌ ស្ថាប័ន និងភាសា រវាងបារាំង និងកម្ពុជា។ ចាប់តាំងពីកម្ពុជាទទួលបានឯករាជ្យមក ការគោរពអធិបតេយ្យ បានក្លាយជាគោលការណ៍ស្នូល ដែលមានបន្តរហូតដល់សព្វថ្ងៃនេះ នៅលើឆាកអន្តរជាតិ តាមរយៈការប្រកាន់ខ្ជាប់នូវធម្មនុញ្ញអង្គការសហប្រជាជាតិ ការគាំទ្រដល់ការរក្សាសន្តិភាព និងការទាមទារឱ្យមានពហុភាគីនិយមប្រកបដោយ

ប្រសិទ្ធភាព ដែលឆ្លុះបញ្ចាំងតាមរយៈការចូលរួមរបស់កម្ពុជា ក្នុងគំនិតផ្តួចផ្តើមបារាំង-មិកស៊ិក ដើម្បីកម្រិតការប្រើប្រាស់សិទ្ធិវេតូ នៅក្រុមប្រឹក្សាសន្តិសុខអ.ស.ប។ ថ្នាក់ដឹកនាំទាំងពីរបានស្វាគមន៍ស្មារតីនៃ «សម្ព័ន្ធភាពនៃប្រទេសឯករាជ្យ» ដែលឯកឧត្តមប្រធានាធិបតី នៃសាធារណរដ្ឋបារាំង បានអំពាវនាវនៅក្នុងកិច្ចសន្ទនា Shangri-La កាលពីខែឧសភា ឆ្នាំ២០២៥ ក្នុងគោលបំណងពង្រឹងភាពធន់ និងអធិបតេយ្យរបស់បណ្តាប្រទេសនៅអឺរ៉ុប និងអាស៊ី ដែលប្រកាន់ខ្ជាប់នូវពហុភាគីនិយម នៅក្នុងបរិបទដែលនិន្នាការមហាអំណាច និងការបំពានលើច្បាប់អន្តរជាតិ បានវិលត្រឡប់មកវិញ។ ថ្នាក់ដឹកនាំទាំងពីរបានប្តេជ្ញាធ្វើឱ្យកិច្ចសហប្រតិបត្តិការកាន់តែស៊ីជម្រៅថែមទៀត នៅក្នុងវេទិកាអន្តរជាតិនានា និងតាមរយៈយន្តការទ្វេភាគីដែលមានស្រាប់ ដោយចាប់ផ្តើមពីកិច្ចពិគ្រោះយោបល់នយោបាយប្រចាំឆ្នាំ រវាងក្រសួងការបរទេស នៃប្រទេសទាំងពីរ។

ពង្រឹងទំនាក់ទំនងសេដ្ឋកិច្ចទ្វេភាគី

៤. ដោយផ្អែកលើការវិវត្តយ៉ាងឆាប់រហ័សនៃសេដ្ឋកិច្ចកម្ពុជា និងការបញ្ចប់ដំណាក់កាលអន្តរកាលនៃការចាកចេញពីឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួចរបស់កម្ពុជានាពេលខាងមុខ ព្រមទាំងផ្អែកលើទំនាក់ទំនងដែលបានតភ្ជាប់ជាមួយភាគីពាក់ព័ន្ធផ្នែកសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់បារាំង ថ្នាក់ដឹកនាំទាំងពីរ បានបញ្ជាក់នូវបំណងបន្តការគាំទ្រកម្ពុជា លើមាគ៌ាអភិវឌ្ឍន៍ប្រកបដោយចីរភាព តាមរយៈការកាត់បន្ថយការពឹងផ្អែកលើកត្តាខាងក្រៅ ការប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ ការបាត់បង់ជីវៈចម្រុះ និងការបំពុលផ្សេងៗ ក្នុងគោលបំណង បម្រើដល់តម្រូវការចាំបាច់ជាមូលដ្ឋានរបស់ប្រជាជនកម្ពុជា។

៥. ក្នុងន័យនេះ ប្រមុខរដ្ឋ និងប្រមុខរដ្ឋាភិបាលនៃប្រទេសទាំងពីរ បានស្វាគមន៍ការរៀបចំវេទិកាធុរកិច្ចបារាំង-កម្ពុជាលើកទី៣ និងបានអញ្ជើញជាអធិបតីក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យា និងអនុស្សរណៈជាច្រើន ពាក់ព័ន្ធនឹងគម្រោងហេដ្ឋារចនាសម្ព័ន្ធប្រកបដោយនិរន្តរភាព និងគុណភាព ជាពិសេសនៅក្នុងវិស័យថាមពល សុខាភិបាល ដឹកជញ្ជូន និងកសិ-ចំណីអាហារ។

៦. ក្នុងបំណងធ្វើឱ្យប្រសើរឡើងនូវក្របខ័ណ្ឌទំនាក់ទំនងសេដ្ឋកិច្ចទ្វេភាគី សេចក្តីប្រកាសបំណងជាច្រើនត្រូវបានចុះហត្ថលេខា ដូចជាសេចក្តីប្រកាសបំណងរវាងអគ្គនាយកដ្ឋានគយបារាំងនិងកម្ពុជា សេចក្តីប្រកាសបំណងរវាងវិទ្យាស្ថានជាតិកម្មសិទ្ធិឧស្សាហកម្មបារាំងនិងក្រសួងពាណិជ្ជកម្មកម្ពុជា ព្រមទាំងរវាងអាជ្ញាធរអាកាសចរណ៍ស៊ីវិលនៃប្រទេសទាំងពីរ។ កិច្ចព្រមព្រៀងអន្តរដ្ឋាភិបាល ស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការក្លែងបន្លំ និងការគេចវេះពន្ធ ក៏ត្រូវបានចុះហត្ថលេខាផងដែរ។

៧. ប្រទេសបារាំង បានបន្តការប្តេជ្ញាចិត្តក្នុងការគាំទ្រកម្ពុជា លើការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ដែលមានរចនាសម្ព័ន្ធច្បាស់លាស់ តាមរយៈការផ្តល់ឥណទានថ្មីៗពីទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ និងការកៀរគរអ្នកជំនាញបច្ចេកទេសបារាំង ដើម្បីគាំទ្រកម្ពុជាក្នុងការអភិវឌ្ឍវិស័យថាមពល មជ្ឈមណ្ឌលជាតិស្រាវជ្រាវបញ្ញាសិប្បនិម្មិត ព្រមទាំងការគ្រប់គ្រងទឹកស្អាតនៅខេត្តសៀមរាប និងប្រព័ន្ធទឹកកខ្វក់ នៅរាជធានីភ្នំពេញ។

ការពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យច្បាប់ និងបណ្ណសារ

៨. ថ្នាក់ដឹកនាំទាំងពីរ បានសម្តែងនូវការពេញចិត្តចំពោះកិច្ចសហប្រតិបត្តិការ ដែលបានបង្កើតឡើង ក្នុងគោលបំណងរួមចំណែកដល់ការអភិវឌ្ឍ និងការលើកកម្ពស់ធនធានមនុស្សក្នុងវិស័យច្បាប់ ព្រមទាំងការ

ពង្រឹងទំនើបកម្ម តម្លាភាព និងលទ្ធភាពទទួលបានព័ត៌មានផ្នែកច្បាប់ សម្រាប់ជាប្រយោជន៍ដល់ប្រជាពលរដ្ឋ ធុរកិច្ច និងរដ្ឋបាលសាធារណៈ។ ថ្នាក់ដឹកនាំទាំងពីរ ក៏បានស្វាគមន៍ចំពោះការចុះហត្ថលេខាលើសេចក្តីប្រកាសបំណង ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យបណ្ណសារ ដែលត្រូវបានចុះហត្ថលេខាក្នុងអំឡុងដំណើរទស្សនកិច្ចផ្លូវរដ្ឋនេះផងដែរ។

ការគាំទ្របរិវត្តកម្មក្នុងវិស័យការពារជាតិ និងសន្តិសុខ

៩. ដោយឆ្នាំ២០២៦ គឺជាខួប ៨០ឆ្នាំ នៃកិច្ចសហប្រតិបត្តិការយោធាបារាំង-កម្ពុជា មេដឹកនាំទាំងពីរមានបំណងពង្រឹងភាពជាដៃគូនេះឱ្យកាន់តែស៊ីជម្រៅ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការកែសម្រួលកងកម្លាំងប្រដាប់អាវុធ តាមរយៈការចុះហត្ថលេខាលើឯកសារបំពេញបន្ថែមចំនួនបី រួមមាន៖ ការបន្តសុពលភាពនិងកែលម្អ កិច្ចព្រមព្រៀងអន្តរដ្ឋាភិបាល ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យការពារជាតិ និងលក្ខន្តិក:នៃកងកម្លាំងប្រដាប់អាវុធ, កិច្ចសម្របសម្រួលរដ្ឋបាលរយៈពេលបីឆ្នាំ (២០២៧-២០៣០) ស្តីពីការជួយគាំទ្រលើការធ្វើទំនើបកម្មកងយោធពលខេមរភូមិន្ទ, ការបណ្តុះបណ្តាលនាយទាហាន និងការបណ្តុះបណ្តាលសម្រាប់ប្រតិបត្តិការរក្សាសន្តិភាព ដោយកំណត់លម្អិតអំពីនីតិវិធីនានានៃកិច្ចសហប្រតិបត្តិការរបស់បារាំង ក្នុងការគាំទ្រដល់ការរៀបចំរចនាសម្ព័ន្ធកងយោធពលខេមរភូមិន្ទឡើងវិញ និងកិច្ចសម្របសម្រួល បច្ចេកទេសរវាងក្រសួងការពារជាតិ នៃប្រទេសទាំងពីរ ទាក់ទងនឹងបម្លាស់ប្តូរបុគ្គលិកយោធាសម្រាប់ការបណ្តុះបណ្តាល តាមរយៈការចងសម្ព័ន្ធមេត្រីភាពរវាងសាលានាយទាហានសកម្មត្មាតពង និងសាលានាយទាហានពិសេសសាំងស៊ៀរ (Saint-Cyr)។ ថ្នាក់ដឹកនាំទាំងពីរ ក៏បានសង្កត់ធ្ងន់ផងដែរ អំពីភាពចាំបាច់នៃការសហការគ្នាឆ្លើយតបនឹងឧក្រិដ្ឋកម្មឆ្លងដែន នាសម័យបច្ចុប្បន្ន។

ពង្រឹងបម្លាស់ប្តូរប្រជាជនឱ្យកាន់តែរឹងមាំ និងមានចីរភាព

១០. ដោយជឿជាក់ថា ទំនាក់ទំនងរវាងរដ្ឋនិងរដ្ឋ អាចចាក់ឫសយ៉ាងរឹងមាំប្រកបដោយចីរភាព ក្នុងសន្តិភាព និងវិបុលភាពបាន លុះត្រាតែទំនាក់ទំនងនោះ ផ្តោតសំខាន់លើការផ្សារភ្ជាប់រវាងប្រជាជននិងប្រជាជន ឯកឧត្តមប្រធានាធិបតី នៃសាធារណរដ្ឋបារាំង និងសម្តេចធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានកោតសរសើរចំពោះតួនាទីដ៏សំខាន់របស់សហគមន៍បារាំង-កម្ពុជា ដែលជាស្ពានតភ្ជាប់យ៉ាងសំខាន់រវាងវប្បធម៌នៃប្រទេសទាំងពីរ និងការចូលរួមចំណែករបស់សហគមន៍ខ្មែរនៅប្រទេសបារាំង ក្នុងការធ្វើបរិវត្តកម្មនៅកម្ពុជា។ ថ្នាក់ដឹកនាំទាំងពីរ ក៏បានសម្តែងនូវការពេញចិត្តចំពោះភាពរស់រវើក នៃការផ្លាស់ប្តូរអ្នកស្ម័គ្រចិត្តអន្តរជាតិ ដែលឆ្លុះបញ្ចាំងនូវចំណងសាមគ្គីភាពមួយបែបទៀតដ៏រឹងមាំ មិនអាចបំបែកបាន ដែលផ្សារភ្ជាប់ប្រជាជនបារាំង និងប្រជាជនកម្ពុជា។

១១. ពាក់ព័ន្ធនឹងភាសាបារាំង **ឯកឧត្តមប្រធានាធិបតី នៃសាធារណរដ្ឋបារាំង** បានអបអរសាទរចំពោះ **សម្តេចធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី** ចំពោះភាពជោគជ័យនៃកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី២០ នៅរាជធានីភ្នំពេញ ដែលបានបញ្ជាក់អំពីភាពរស់រវើករបស់អង្គការហ្វ្រង់កូហ្វូនីនៅក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក។ ក្នុងឱកាសនោះ បារាំង និងកម្ពុជា បានបញ្ជាក់ជាថ្មីនូវការប្រកាន់ខ្ជាប់ចំពោះគុណតម្លៃ និងបេសកកម្មរបស់ហ្វ្រង់កូហ្វូនី ជាពិសេសការលើកកម្ពស់ភាសាបារាំង ក្នុងនាមជាភាសានៃឱកាស និងសមត្ថភាពក្នុងការទទួលបានការងារ ការធ្វើដំណើរសហប្រតិបត្តិការ និងការទទួលបានចំណេះដឹង។ បារាំង និងកម្ពុជា មានបំណងរួមចំណែកដល់ការរៀបចំរចនា

សម្ព័ន្ធ និងការអភិវឌ្ឍសេដ្ឋកិច្ចហ្វ្រង់កូហ្វូនី អនុលោមតាមទិសដៅនៃកិច្ចប្រជុំកំពូល និងរួមគ្នាជំរុញមហិច្ឆតានេះ នៅក្នុងអង្គការអន្តរជាតិហ្វ្រង់កូហ្វូនី។ ក្នុងន័យនេះ ថ្នាក់ដឹកនាំទាំងពីរ បានអញ្ជើញជាអធិបតីរួមគ្នា ក្នុងពិធីសម្ពោធព្រឹត្តិការណ៍ FrancoTech លើកទី២ ដែលជាពិព័រណ៍ ស្តីពីនវានុវត្តន៍ជាភាសាបារាំង។ ថ្នាក់ដឹកនាំទាំងពីរមានសេចក្តីសោមនស្សរីករាយ ដែលកិច្ចប្រជុំកំពូលនេះ បានក្លាយជាឱកាសបង្ហាញពីតម្លៃបន្ថែមនៃភាសាបារាំង ក្នុងការពង្រឹងសន្តិភាព ស្ថិរភាព និងវិបុលភាព ជាពិសេសតាមរយៈការរួមចំណែករបស់កម្ពុជា ក្នុងប្រតិបត្តិការរក្សាសន្តិភាព នៅក្នុងមជ្ឈដ្ឋានប្រើប្រាស់ភាសាបារាំង។ បារាំង និងកម្ពុជា ក៏បានអះអាងជាថ្មីនូវការប្តេជ្ញាចិត្តចំពោះសមភាពរវាងស្ត្រី និងបុរស និងការលើកកម្ពស់សិទ្ធិស្ត្រី បន្តពីសេចក្តីថ្លែងការណ៍ ដែលបានអនុម័ត ក្នុងកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី១៩ និងសេចក្តីអំពាវនាវទីក្រុងគីហ្គាលី ស្តីពី «ការពន្លឿនវឌ្ឍនភាពឆ្ពោះទៅរកសមភាពរវាងស្ត្រី និងបុរស នៅក្នុងតំបន់និយាយភាសាបារាំង» ដែលត្រូវបានអនុម័ត ក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រីហ្វ្រង់កូហ្វូនីលើកទី៤៦។

១២. ក្នុងវិស័យវប្បធម៌ និងបេតិកភណ្ឌ ដំណើរទស្សនកិច្ចផ្លូវរដ្ឋរបស់ប្រធានាធិបតី នៃសាធារណរដ្ឋបារាំង ត្រូវបានកត់សម្គាល់ដោយពិធីបិទបញ្ចប់ការដ្ឋានជួសជុលប្រាសាទមេបុណ្យខាងលិច នៅតំបន់អង្គរ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។ ការវិនិយោគក្នុងរយៈពេល ១៤ ឆ្នាំ ក្នុងទំហំទឹកប្រាក់ ៧ លានអឺរ៉ូ ក្នុងការលើកតម្កើងបេតិកភណ្ឌខ្មែរនេះ គឺជាការឆ្លុះបញ្ចាំងពីស្មារតីនៃការប្តេជ្ញាចិត្តរបស់បារាំងជាមួយកម្ពុជា នៅក្នុងក្របខ័ណ្ឌនៃគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍន៍តំបន់អង្គរ។

១៣. ទន្ទឹមនឹងនេះ រដ្ឋាភិបាលបារាំង និងរាជរដ្ឋាភិបាលកម្ពុជា បានបើកទំព័រថ្មីមួយ ក្នុងវិស័យសហប្រតិបត្តិការវប្បធម៌ និងបេតិកភណ្ឌ តាមរយៈការចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាច្រើន ដែលក្នុងនោះកិច្ចព្រមព្រៀងមួយមានគោលបំណងគាំទ្រដល់ការលើកតម្កើងបេតិកភណ្ឌកម្ពុជា ទាំងនៅក្នុងប្រទេស និងនៅលើឆាកអន្តរជាតិ តាមរយៈការអភិវឌ្ឍភាពជាដៃគូសំខាន់មួយ សម្រាប់គម្រោងធ្វើទំនើបកម្មសារមន្ទីរជាតិ នៅរាជធានីភ្នំពេញ ក្នុងការបន្តសិក្សាសមិទ្ធិលទ្ធភាព ដែលប្រទេសបារាំងបានធ្វើចាប់ពីឆ្នាំ២០២៦។ រដ្ឋាភិបាលទាំងពីរក៏បានសម្រេចនូវការចុះហត្ថលេខាលើសេចក្តីប្រកាសបំណងរួម ស្តីពីការបង្កើតឱ្យមានបម្លាស់ប្តូរ និងការពង្រឹងវិជ្ជាជីវៈ ក្នុងវិស័យឧស្សាហកម្មវប្បធម៌ច្នៃប្រតិដ្ឋ ជាពិសេសក្នុងវិស័យភាពយន្ត និងសោតទស្សន៍ សិល្បៈទស្សនីយភាព សៀវភៅ សិល្បៈសម្តែង ព្រមទាំងការបង្កើតស្នាដៃនិងការបណ្តុះបណ្តាលផ្នែកសិល្បៈ។

១៤. ដោយសង្កត់ធ្ងន់លើតួនាទីដ៏សំខាន់ នៃភាពជាដៃគូរវាងសាកលវិទ្យាល័យ និងបម្លាស់ទីនិស្សិតសម្រាប់ការសិក្សា ក្នុងការរួមចំណែកដល់ការអភិវឌ្ឍចំណេះដឹងនិងជំនាញ ថ្នាក់ដឹកនាំទាំងពីរ បានសម្តែងការកោតសរសើរចំពោះការចាក់ឫសយ៉ាងរឹងមាំ នៃការប្រើប្រាស់ភាសាបារាំង នៅតាមគ្រឹះស្ថានឧត្តមសិក្សាប្រកបដោយឧត្តមភាព ជាពិសេសក្នុងវិស័យច្បាប់ វិទ្យាសាស្ត្រសុខាភិបាល ព្រមទាំងវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងវិស្វកម្ម តាមរយៈគោលនយោបាយប្រកបដោយឆន្ទៈមោះមុតរបស់គ្រឹះស្ថានឧត្តមសិក្សាឈានមុខគេរបស់កម្ពុជា និងដៃគូបារាំង។ ឯកឧត្តមប្រធានាធិបតី ក៏បានសម្តែងនូវការពេញចិត្តចំពោះភាពទាក់ទាញរបស់បារាំង ក្នុងវិស័យនវានុវត្តន៍ និងបច្ចេកវិទ្យាទំនើបឈានមុខ ដូចជា វិស័យអវកាស ឌីជីថល និងបញ្ញាសិប្បនិម្មិត។ ក្នុងន័យនេះ ឯកឧត្តមប្រធានាធិបតី បានស្វាគមន៍ចំពោះកិច្ចព្រមព្រៀង ដែលបានចុះហត្ថលេខារវាងសាកលវិទ្យាល័យ Grenoble-Alpes និងបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា (CADT) លើវិស័យទាំងនេះ។ ឯកឧត្តម

ប្រធានាធិបតី ក៏បានគូសបញ្ជាក់ផងដែរអំពីការប្តេជ្ញាចិត្តរបស់បារាំង ក្នុងការគាំទ្រដំណើរការអភិវឌ្ឍការស្រាវជ្រាវនៅកម្ពុជា តាមរយៈការបង្កើតសាលាថ្នាក់បណ្ឌិត ក្នុងវិស័យដែលជាផលប្រយោជន៍រួម។ ភាគីទាំងពីរក៏នឹងលើកទឹកចិត្តដល់ភាពជាដៃគូរវាងគ្រឹះស្ថានឧត្តមសិក្សា ស្ថាប័នស្រាវជ្រាវ និងតួអង្គសេដ្ឋកិច្ចនានា ក្នុងការគាំទ្រដល់ការស្រាវជ្រាវ អនុវត្ត និងកៀរគរអ្នកស្រាវជ្រាវ និងនិស្សិតផងដែរ។

១៥. ថ្នាក់ដឹកនាំទាំងពីរ បានគូសបញ្ជាក់អំពីភាពចាស់ទុំ ស៊ីជម្រៅ និងប្រកបដោយថាមវន្ត នៃកិច្ចសហប្រតិបត្តិការវិមជ្ឈការ ដែលបានរួមចំណែកអស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ ក្នុងការពង្រឹងមូលដ្ឋានគ្រឹះដ៏រឹងមាំ នៃទំនាក់ទំនងទ្វេភាគី។ ថ្នាក់ដឹកនាំទាំងពីរ បានកោតសរសើរចំពោះការប្តេជ្ញាចិត្តរបស់អាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិបារាំង និងកម្ពុជា ក្នុងការអនុវត្តភាពជាដៃគូ ដែលផ្អែកលើការផ្លាស់ប្តូរជំនាញបច្ចេកទេស ការពង្រឹងសមត្ថភាពមូលដ្ឋាន និងការអនុវត្តគម្រោងជាក់ស្តែង ក្នុងវិស័យដែលជាផលប្រយោជន៍រួម ជាពិសេសការទទួលបានសេវាមូលដ្ឋានចាំបាច់ សុខាភិបាល អប់រំ ការគ្រប់គ្រងនគរូបនីយកម្ម បរិស្ថាន និងការលើកតម្កើងបេតិកភណ្ឌ។ ថ្នាក់ដឹកនាំទាំងពីរ បានអះអាងជាថ្មីនូវឆន្ទៈក្នុងការគាំទ្រដល់ការបន្តសុពលភាព និងការពង្រីកភាពជាដៃគូទាំងនេះ ដើម្បីបម្រើដល់ការអភិវឌ្ឍប្រកបដោយចីរភាព បរិយាបន្ន និងសមភាពនៅតាមតំបន់។

រួមគ្នាឆ្លើយតបបញ្ហាប្រឈមជាសកល

១៦. ដោយទទួលស្គាល់ថា ការជំរុញវឌ្ឍនភាព នៃចំណេះដឹងវិទ្យាសាស្ត្រ ការស្រាវជ្រាវ និងនវានុវត្តន៍ ដើម្បីបម្រើដល់មនុស្សជាតិ ដល់ផលប្រយោជន៍សាធារណៈ ដល់ភពផែនដី និងដល់វឌ្ឍនភាពសម្រាប់ប្រជាជន គឺជារឿងដ៏សំខាន់បំផុត **ឯកឧត្តមប្រធានាធិបតី** នៃសាធារណរដ្ឋបារាំង និង **សម្តេចធិបតីនាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា បានសម្តែងនូវការពេញចិត្តចំពោះទស្សនៈស្របគ្នារបស់ប្រទេសទាំងពីរ អំពីទំនួលខុសត្រូវដែលត្រូវរ៉ាប់រងរួមគ្នា ក្នុងការដោះស្រាយបញ្ហាប្រឈមជាសកល។ ថ្នាក់ដឹកនាំទាំងពីរ បានគូសបញ្ជាក់អំពីសារៈសំខាន់នៃការពង្រឹងកិច្ចសហប្រតិបត្តិការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ក្នុងវិស័យដែលជាផលប្រយោជន៍រួម ជាពិសេសវិស័យកសិកម្មប្រកបដោយចីរភាព សន្តិសុខស្បៀង ថាមពល សុខាភិបាល ការគ្រប់គ្រងធនធានទឹក និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ តាមរយៈការលើកកម្ពស់ការចែករំលែកចំណេះដឹង និងការអភិវឌ្ឍដំណោះស្រាយ ដែលសមស្របទៅនឹងបរិបទមូលដ្ឋាន។

១៧. ក្នុងន័យនេះ ថ្នាក់ដឹកនាំទាំងពីរ បានអះអាងអំពីភាពចាំបាច់នៃការពន្លឿនសកម្មភាពរួមគ្នា ប្រឆាំងនឹងវិបត្តិភពផែនដីចំនួនបី ដែលរួមមាន ការប្រែប្រួលអាកាសធាតុ ការបាត់បង់ជីវៈចម្រុះ និងការបំពុលផ្សេងៗ។ ដើម្បីកំណត់ការកើនឡើងកម្តៅផែនដីឱ្យនៅត្រឹម ១,៥ អង្សាសេ ភាគីទាំងពីរបានបញ្ជាក់ពីការប្តេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការសម្រេចឱ្យបានពេញលេញនូវគោលដៅ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស តាមរយៈផែនការជាតិរួមចំណែកឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ប្រកបដោយមហិច្ឆតា និងការអនុវត្តការប្តេជ្ញាចិត្ត ក្នុងការចាកចេញជាបណ្តើរៗពីការប្រើប្រាស់ឥន្ធនៈហ្វូស៊ីល ដោយពន្លឿនការប្រើប្រាស់ថាមពលអគ្គិសនី ដែលមានកាបូនទាប។ ប្រទេសបារាំង នឹងបន្តគាំទ្រដល់គោលដៅរបស់កម្ពុជាក្នុងការសម្រេចឱ្យបាននូវអព្យាក្រឹតភាពកាបូននៅត្រឹមឆ្នាំ២០៥០ ក៏ដូចជាការប្តេជ្ញាចិត្តរបស់កម្ពុជា ក្នុងការមិនអភិវឌ្ឍរោងចក្រអគ្គិសនីដើរដោយធ្យូងថ្មថ្មីបន្ថែមទៀត។ ថ្នាក់ដឹកនាំទាំងពីរ បានសង្កត់ធ្ងន់ អំពីការប្តេជ្ញាចិត្តក្នុងការការពារតួនាទីវិទ្យាសាស្ត្រជា

មូលដ្ឋានគ្រឹះ នៃសកម្មភាពអាកាសធាតុ និងបានទទួលស្គាល់សារៈសំខាន់នៃរបាយការណ៍របស់ក្រុមប្រឹក្សាអន្តរ រដ្ឋាភិបាល ស្តីពីការប្រែប្រួលអាកាសធាតុ ជាការរួមចំណែកដ៏សំខាន់សម្រាប់ការវាយតម្លៃជាសកលលើកទី២។ ថ្នាក់ដឹកនាំទាំងពីរ ក៏មានបំណងបន្តធ្វើការរួមគ្នា ជាពិសេសដើម្បីឈានទៅអនុវត្តឱ្យបានពេញលេញនូវក្របខ័ណ្ឌ សកលស្តីពីជីវៈចម្រុះ Kunming-Montréal និងកិច្ចព្រមព្រៀង BBNJ ដែលជាកត្តាកំណត់ដ៏សំខាន់ ធានាឱ្យ បាននូវកិច្ចការពារកាន់តែប្រសើរឡើងចំពោះជីវៈចម្រុះ និងមហាសមុទ្រ។ លើសពីនេះ ភាគីទាំងពីរបាន បញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្ត ក្នុងការប្រយុទ្ធប្រឆាំងនឹងការកាប់បំផ្លាញព្រៃឈើ ព្រមទាំងដើម្បីលើកកម្ពស់ សេដ្ឋកិច្ចវិលជុំ និងបញ្ចប់ការចរចាលើលិខិតបករណ៍អន្តរជាតិ ដែលមានកាតព្វកិច្ចផ្លូវច្បាប់ ដើម្បីបញ្ឈប់ការ បំពុលដោយប្លាស្ទិក។

១៨. ម្យ៉ាងវិញទៀត ថ្នាក់ដឹកនាំទាំងពីរ បានសម្តែងនូវសេចក្តីរីករាយចំពោះការចូលជាសមាជិករបស់កម្ពុជា ក្នុងភាពជាដៃគូសកល ស្តីពីបញ្ញាសិប្បនិម្មិត។ **ឯកឧត្តមប្រធានាធិបតី** នៃសាធារណរដ្ឋបារាំង និង**សម្តេចធិបតី នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា បានប្រកាសពីការប្រកាន់ខ្ជាប់នូវបញ្ញាសិប្បនិម្មិតមួយប្រកបដោយ ក្រមសីលធម៌ បរិយាបន្ន សុវត្ថិភាព និងគួរឱ្យទុកចិត្តបាន ព្រមទាំងការលើកកម្ពស់អភិបាលកិច្ចប្រកបដោយ ប្រជាធិបតេយ្យ និងតម្លាភាពលើធនធាន ដែលបញ្ញាសិប្បនិម្មិតផ្តល់ឱ្យ និងការកាត់បន្ថយគម្លាតសកល ក្នុងវិស័យនេះ។ គម្រោងបង្កើតមជ្ឈមណ្ឌលជាតិស្រាវជ្រាវបញ្ញាសិប្បនិម្មិត ដែលបារាំង នឹងសហការផ្តល់ ហិរញ្ញប្បទានតាមរយៈទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ គឺជាផ្នែកមួយនៃចក្ខុវិស័យរួមគ្នានេះ។

១៩. ដោយរំលឹកឡើងវិញ អំពីការប្តេជ្ញាចិត្តដែលបានធ្វើឡើងក្នុងក្របខ័ណ្ឌនៃកិច្ចប្រជុំកំពូលសុខភាពតែមួយ (នៅទីក្រុងលីយ៉ុង ថ្ងៃទី៥-៧ ខែមេសា ឆ្នាំ២០២៦) ដើម្បីគាំទ្រដល់ការអនុវត្តអភិក្រម «សុខភាពតែមួយ» ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺឆ្លង និងជំងឺមិនឆ្លង ថ្នាក់ដឹកនាំទាំងពីរ ក៏បានបញ្ជាក់ជាថ្មីផងដែរនូវឆន្ទៈក្នុងការ រក្សាកិច្ចសហប្រតិបត្តិការ សម្រាប់ជាប្រយោជន៍ដល់ឧត្តមភាពនៃការបណ្តុះបណ្តាលវេជ្ជសាស្ត្រជាភាសា បារាំងនៅកម្ពុជា (សញ្ញាបត្របណ្តុះបណ្តាលវេជ្ជសាស្ត្រឯកទេស និងសញ្ញាបត្របណ្តុះបណ្តាលវេជ្ជសាស្ត្រ ឯកទេសជាន់ខ្ពស់ ព្រមទាំងការបង្រៀនជំនាញឯកទេស)។ ថ្នាក់ដឹកនាំទាំងពីរ ក៏បានសម្រេចចិត្តធ្វើឱ្យភាពជា ដៃគូនេះកាន់តែស៊ីជម្រៅ និងពង្រីកវិសាលភាពបន្ថែមទៀត តាមរយៈការដាក់ឱ្យអនុវត្តជាក់ស្តែងនូវអភិក្រម «សុខភាពតែមួយ» ជាពិសេសដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាត ដោយគាំទ្រដល់ការអភិវឌ្ឍសមត្ថភាព ស្រាវជ្រាវរបស់កម្ពុជាលើទិសដៅសំខាន់ៗចំនួនពីរ ដូចជា (១) ការបង្កើតវេទិកាស្រាវជ្រាវអន្តរជាតិផ្នែកសុខភាព សកល(PRISME) បារាំង-កម្ពុជា ដែលនឹងបង្កើតឱ្យមានសន្ទុះអន្តរវិស័យ ក្នុងភាពជាដៃគូជាមួយបណ្ឌិត្យ សភាជាតិវេជ្ជសាស្ត្រ វិទ្យាស្ថានស្រាវជ្រាវចំនួនប្រាំ និងសាកលវិទ្យាល័យ Aix-Marseille និង(២)ការពង្រឹង ការស្រាវជ្រាវផ្នែកកសិកម្ម និងបរិស្ថាន ជាពិសេសក្នុងវិស័យបង្ការ និងកាត់បន្ថយការបំពុលបរិស្ថាន។ កិច្ចសហប្រតិបត្តិការនេះ ក៏នឹងជួយជំរុញការស្រាវជ្រាវលើទំនាក់ទំនងរវាងការបំពុលបរិស្ថាន ការបំពុលប្រព័ន្ធ អេកូឡូស៊ី និងសុខភាពមនុស្ស និងសត្វ ព្រមទាំងដំណោះស្រាយប្រកបដោយនវានុវត្តន៍ ក្នុងការកាត់បន្ថយ សំណល់ប្លាស្ទិក និងការលើកកម្ពស់សេដ្ឋកិច្ចវិលជុំផងដែរ។ ក្នុងន័យនេះ ថ្នាក់ដឹកនាំទាំងពីរ បានស្វាគមន៍ ចំពោះការសម្រេចបាននូវកិច្ចព្រមព្រៀង ស្តីពីកិច្ចសហប្រតិបត្តិការកសិកម្មនិងបរិស្ថាន លើផ្នែកបច្ចេកទេស វិទ្យាសាស្ត្រ និងពាណិជ្ជកម្ម។